## កម្រងសិទ្ធិនៃ

# អ្នកបោះឆ្នោត

## អ្នកមានសិទ្ធិដូចខាងក្រោម៖

1. **សិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ។** អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នក៖
   - ជាពលរដ្ឋអាមេរិកាំងដែលរស់នៅរដ្ឋ California
   - យ៉ាងហោចណាស់មានអាយុ 18 ឆ្នាំ
   - បានចុះឈ្មោះនៅកន្លែងដែលអ្នកកំពុងរស់នៅបច្ចុប្បន្ន
   - បច្ចុប្បន្ននេះមិនជាប់ក្នុងពន្ធនាគាររដ្ឋ ឬសហព័ន្ធ សម្រាប់ការផ្តន្ទាទោសបទឧក្រិដ្ឋ និង
   - បច្ចុប្បន្ននេះ តុលាការមិនបានរកឃើញថា អ្នកអស់មត្ថភាពផ្លូវចិត្ត ក្នុងការបោះឆ្នោតនោះទេ

2. **សិទ្ធិក្នុងការបោះឆ្នោត បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះរួចហើយ ទោះបីជាឈ្មោះរបស់អ្នកមិនមាននៅក្នុងបញ្ជីក៏ដោយ។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់បញ្ចូល បើសិនមន្ត្រីបោះឆ្នោតកំណត់ថាអ្នកមានលក្ខណៈសម្បត្តិ ដើម្បីបោះឆ្នោត។

3. **សិទ្ធិក្នុងការបោះឆ្នោត បើសិនអ្នកនៅតែស្ថិតនៅក្នុងជួររង់ចាំនៅពេលដែលការិយាល័យបោះ ឆ្នោតត្រូវបិទ។**

4. **សិទ្ធិក្នុងការបោះសន្លឹកឆ្នោតសម្ងាត់** ដោយគ្មាននរណាំរំខានអ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5. **សិទ្ធិទទួលបានសន្លឹកឆ្នោតថ្មី បើសិនអ្នកបានធ្វើខុស** បើសិនអ្នកមិនទាន់បានបោះឆ្នោតទេ។ អ្នកអាច៖

   **ស្នើសុំមន្ត្រីបោះឆ្នោតនៅកន្លែងបោះឆ្នោត** រកសន្លឹកឆ្នោតថ្មី

   **ប្តូរសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក** រកសន្លឹកឆ្នោតថ្មីមួយនៅការិយាល័យបោះឆ្នោត ឬនៅការិយាល័យបោះឆ្នោតរបស់អ្នក ឬ

   **បោះឆ្នោតដោយការប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។**

6. **សិទ្ធិទទួលបានជំនួយក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក** ពីនរណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែពីនិយោជក ឬ តំណាងសហជីពរបស់អ្នកតែប៉ុណ្ណោះ។

7. **សិទ្ធិដាក់សន្លឹកឆ្នោតបោះ-តាម-សំបុត្ររបស់អ្នក ដែលបានបំពេញរួចរាល់នៅកន្លែងបោះឆ្នោតណាមួយ** នៅក្នុងរដ្ឋ California។

8. **សិទ្ធិទទួលបានឯកសារបោះឆ្នោតជាភាសាមួយក្រៅពីភាសាអង់គ្លេស** បើសិនមានអ្នកបោះឆ្នោតគ្រប់គ្រាន់នៅក្នុង មណ្ឌលបោះឆ្នោតរបស់អ្នកនិយាយភាសានោះ។

9. **សិទ្ធិ ក្នុងការ សួរសំនួរ ទៅ មន្ត្រីបោះឆ្នោត អំពី នីតិវិធី បោះឆ្នោត** និងមើល ពីដំណើរការបោះឆ្នោត។ បើសិនបុគ្គលដែលអ្នកសួរមិនអាចឆ្លើយតបនឹងសំនួររបស់អ្នកបាន នោះពួកគេត្រូវតែបញ្ជូនអ្នកទៅកាន់បុគ្គលដែលអាចឆ្លើយបាន ដើម្បីឆ្លើយសំនួររបស់អ្នក។ ប្រសិនបើអ្នកបង្កការរំខាន ពួកគេអាចឈប់ឆ្លើយនឹងអ្នក។

10. **សិទ្ធិ រាយការណ៍ អំពី សកម្មភាព បោះឆ្នោតខុសច្បាប់ ឬក្លែងបន្លំ** ទៅ មន្ត្រីបោះឆ្នោត ឬការិយាល័យ រដ្ឋលេខាធិការ។

    - នៅលើគេហទំព័រ **www.sos.ca.gov**
    - តាមទូរសព្ទលេខ **(888) 345-4917**
    - តាមអ៊ីមែល **elections@sos.ca.gov**

---

**បើសិនអ្នកជឿថា អ្នកត្រូវបានគេបដិសេធចំពោះសិទ្ធិណាមួយទាំងអស់នេះ** សូមហៅទូរសព្ទទៅលេខសម្ងាត់របស់ការិយាល័យរដ្ឋលេខាធិការ ដោយឥតគិតថ្លៃបណ្តាញទូរសព្ទទាន់ហេតុការណ៍អ្នកបោះឆ្នោតតាមលេខ **(888) 345-4917។**